

ISSUE #101

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ផ្លូវទៅរកការស្គាល់ព្រះជាម្ចាស់

ព្រះបានប្រោសលោះលោកអ្នកសម្រាប់គោលបំណងដ៏ពិសេសមួយ

"ការស្គាល់ព្រះជាម្ចាស់ដោយទំនាក់ទំនងផ្ទាល់ខ្លួន គឺជាគោលបំណងចុងក្រោយនៃការប្រោសលោះរបស់យើង" ។ ពាក្យនេះរបស់លោក ដេរេក ព្រីនស៍ បានសង្ខេបយ៉ាងល្អឥតខ្ចោះអំពីប្រធានបទ និងគោលបំណងនៃសៀវភៅរបស់គាត់ដែមានចំណងជើងថា ផ្លូវទៅរកការស្គាល់ព្រះជាម្ចាស់ ។ អត្ថបទនេះត្រូវបានដកស្រង់ចេញពីមរតកនៃសេចក្តីបង្រៀនដ៏មានតម្លៃរបស់លោក ដេរេក ព្រីនស៍។

ឮការអធិស្ឋានដែលស្គាល់ព្រះនៃខ្លួន
គេនឹងមានចិត្តរឹងប៉ឹង ហើយនឹងប្រតិបត្តិតាម ។
ដានីយ៉ែល 11:32

និន្នាការដែលគួរឱ្យព្រួយបារម្ភ

បន្ទាប់ពីការចូលរួមយ៉ាងសកម្មក្នុងកិច្ចការរបស់ព្រះអស់រយៈពេលជិតចិតសិបឆ្នាំ នៅក្នុងប្រទេសជាច្រើន ខ្ញុំបានឃើញអំពើអាក្រក់កើនឡើងនៅក្នុងពិភពលោក ក្នុងអត្រាដ៏គួរឲ្យភ្ញាក់ផ្អើល។ ការធ្លាក់ចុះដែលខ្ញុំបានឃើញ អាចពិពណ៌នាបានត្រឹមតែថា ជាការដួលរលំដ៏ធំសម្បើមប៉ុណ្ណោះ។ ការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងសីលធម៌ ទំនាក់ទំនង និងជីវិតគ្រួសារ បាននាំឲ្យមានអំពើហឹង្សា ការកើនឡើងនៃអត្រាលែងលះ និងការបង្ហាញអំពើអាក្រក់ដោយបើកចំហ ក្នុងទម្រង់នៃរបៀបរស់នៅដែលបង្ហូចខាងផ្លូវភេទ។ នៅពេលខ្ញុំក្រឡេកមើលទៅការធ្លាក់ចុះដែលខ្ញុំបានឃើញ ខ្ញុំសួរខ្លួនឯងថា៖ "តើរឿងទាំងអស់នេះបានកើតឡើងក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះឬ?"

យើងកំពុងរស់នៅក្នុងសម័យកាលមួយដែលពោរពេញដោយការផ្លាស់ប្តូរឥតឈប់ឈរ ដ៏ហិង្សា និងមិនអាចគ្រប់គ្រងបាន ជាសម័យដែលព្រះយេស៊ូវបានទាយទុកថា *"មនុស្សនឹងស្រយុតចិត្តដោយភ័យ"* (លូកា 21:26) នៅពេលយើងឃើញការធ្លាក់ចុះដែលកំពុងកើតឡើងលើផែនដី សំណួរមួយកើតឡើងក្នុងចិត្តខ្ញុំថា៖ "តើរាស្ត្ររបស់ព្រះនឹងរកកម្លាំងមកពីណា ដើម្បីឈរយ៉ាងរឹងមាំនៅកណ្តាលរលកនៃអំពើអាក្រក់ ដែលកំពុងកើនឡើងនេះ ហើយយកឈ្នះលើវា? តើពួកគេនឹងរកកម្លាំងមកពីណា ដើម្បីរក្សាភាពស្មោះត្រង់ចំពោះជំនឿរបស់ខ្លួន?"

ខ្លះដែរ។ ប៉ុន្តែ សូមអរព្រះគុណព្រះជាម្ចាស់ ខ្ញុំតែងតែត្រឡប់មករកសេចក្តីពិតនេះវិញ៖ ព្រះយេស៊ូវគឺជា *"អាលផា នឹងអូមេកា គឺជាមុនគេ ហើយក្រោយគេ ជាដើម ហើយជាចុង"* (វិវរណៈ 22:13)។ និងជា *"មេផ្តើម ហើយជាមេ សម្រេចសេចក្តីជំនឿរបស់យើង"* (ហេព្រើរ 12:2)។ យើងបានពេញលេញនៅក្នុងទ្រង់។



នៅពេលណាដែលមនុស្សចាប់ផ្តើមស្វែងរកអ្វីមួយ ក្រៅពីព្រះយេស៊ូវគ្រីស្ទ ពួកគេនឹងរកឃើញទ្រឹស្តី និងគោលលទ្ធិជាច្រើនដែលគួរឱ្យចាប់អារម្មណ៍។ ប៉ុន្តែចុងក្រោយ ពួកគេនឹងឃើញ ដូចកូនពៅវង្វេងថា ពួកគេកំពុងបរិភោគសំបកដែលជ្រូកស៊ី ខណៈដែលពួកគេអាចរស់នៅដោយនំប៉័ងរបស់ព្រះវរបិតាបាន!

សម្រាប់យើងជាអ្នកជឿទាំងអស់គ្នា វាអាចទៅរួចដែលយើងស្គាល់ព្រះគម្ពីរយ៉ាងស្ទាត់ជំនាញ អានសៀវភៅលើកទឹកចិត្តជាច្រើនក្បាល ចូលរួមសន្និសីទពី១ឆ្នាំទៅ១ឆ្នាំ និងស្តាប់អ្នកអធិប្បាយល្អបំផុត នៅក្នុងពិភពលោក ប៉ុន្តែ យើងនៅតែអាចខកខានគោលបំណងសំខាន់ក្នុងជីវិតបាន។ តើអ្វីគឺជាគោលបំណងពិតប្រាកដរបស់អ្នក? តើអ្វីជាបទពិសោធន៍ដ៏ខ្ពង់ខ្ពស់បំផុតដែលបំពេញគោលបំណង ដែលព្រះបានប្រោសលោះអ្នក? គឺ ការស្គាល់ព្រះអង្គផ្ទាល់។ ចំណេះដឹងអំពីអ្វីផ្សេងទៀត មិនថាល្អ ឬត្រឹមត្រូវប៉ុណ្ណា ក៏មិនអាចបំពេញបំណងចិត្តដ៏ជ្រាលជ្រៅអ្នកបានឡើយ។ មានតែទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះជាម្ចាស់ផ្ទាល់តាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះដែលអាចសម្រេចការនេះបាន។

ដូច្នេះ បើអ្នករកឃើញខ្លួនឯងចូលចិត្តសិក្សាទស្សនវិជ្ជារបស់មនុស្ស ដើម្បីស្វែងរកចម្លើយចុងក្រោយសម្រាប់ជីវិតរបស់អ្នក ខ្ញុំសូមណែនាំឲ្យអ្នកពិនិត្យមើលចិត្តរបស់អ្នក។ តើអ្នកកំពុងស្វែងរកអ្វី? តើអ្នកកំពុងស្វែងរកចំណេះដឹងបន្ថែមអំពីព្រះ ឬកំពុងស្វែងរកទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះ? មុនពេលអ្នកបិទភ្នែកគេងនៅយប់នេះ ចូរចាប់យកឱកាសនេះ ដើម្បីកំណត់ការស្គាល់ព្រះដោយផ្ទាល់ខ្លួន ជាគោលដៅខ្ពស់បំផុតនៃការស្វែងរករបស់អ្នក។ នៅពេលអ្នកស្គាល់ទ្រង់ដោយផ្ទាល់ អ្នកកំពុងដើរលើផ្លូវទៅរកសុវត្ថិភាពពិតប្រាកដ។ មានតែពេលនោះទេ ដែលអ្នកនឹងបំពេញគោលបំណងដែលព្រះមានសម្រាប់ជីវិតរបស់អ្នកយ៉ាងពិតប្រាកដ។

តើនេះជាបំណងប្រាថ្នារបស់អ្នកដែរឬទេ? បើដូច្នោះមែន ចូរយើងបង្ហាញបំណងប្រាថ្នានោះរួមគ្នា តាមរយៈសេចក្តីអធិស្ឋានខាងក្រោម៖

សេចក្តីអធិស្ឋាន

ព្រះអម្ចាស់អើយ! ទូលបង្គំប្រាថ្នាចង់បានតែទ្រង់ គឺទ្រង់តែមួយអង្គគត់។ សូមអត់ទោសឲ្យទូលបង្គំផង ដែលទូលបង្គំបានបណ្តោយឲ្យការស្វែងរកអ្វីផ្សេងៗ រំខានដល់ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ទូលបង្គំជាមួយទ្រង់។ តាមរយៈសេចក្តីអធិស្ឋាននេះ ទូលបង្គំប្តេជ្ញាចិត្តទាំងស្រុង ដើម្បីស្គាល់ទ្រង់ឲ្យបានកាន់តែច្បាស់ថែមទៀត។ អាម៉ែន។

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សេចក្តីបង្រៀនជាលិខិតរបស់លោកដេរេក ព្រីនស៍ អាចទាញយកដោយឥតគិតថ្លៃពីគេហទំព័ររបស់យើង www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

មនុស្សមានចិត្តរឹងប៉ឹង

ពិភពលោកដែលត្រូវបានពិពណ៌នានៅចុងបញ្ចប់នៃគម្ពីរដានីយ៉ែល ក៏អាចពិពណ៌នា អំពីពិភពលោកដែលយើងកំពុងរស់នៅសព្វថ្ងៃនេះបានដែរ។ ពិភពលោកនៅសម័យដានីយ៉ែល គឺជាកន្លែងដែលអំពើអាក្រក់ និងការប្រឆាំងនឹងព្រះ និងផ្លូវរបស់ទ្រង់កំពុងតែកើនឡើង។ គម្ពីរនេះបានទាយទុកជាមុនអំពីសម័យកាលមួយ ដែលអំពើអាក្រក់នឹងមានអំណាចយ៉ាងខ្លាំង ដោយបោសសម្អាតស្ទើរតែគ្រប់យ៉ាងដែលនៅខាងមុខវា។ ទោះជាយ៉ាងណាក៏ដោយ ដានីយ៉ែលក៏បានពិពណ៌នា អំពីមនុស្សមួយប្រភេទ ដែលនឹងមិនត្រូវបានគ្របដណ្តប់ដោយទឹកជំនន់នៃអំពើអាក្រក់នោះឡើយ ជាមនុស្សដែលនឹងមានសកម្មភាព ទទួលបានជោគជ័យ និងមានជ័យជម្នះនៅកណ្តាលស្ថានភាពនោះ៖

ឯពួកអ្នកដែលប្រព្រឹត្តអាក្រក់ទាស់នឹងសេចក្ដីសញ្ញា នោះវានឹងនាំបង្ខូចចិត្តគេ ដោយពាក្យបញ្ចើច តែចំណែកពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន គេនឹងមានចិត្តរឹងប៉ឹង ហើយនឹងប្រតិបត្តិតទៅ ។

***ដានីយ៉ែល** 11:32*

ការបកប្រែ New International Version (NIV) ចែងថា រាស្ត្ររបស់ព្រះ "នឹងឈររឹងមាំប្រឆាំង" នឹងស្តេចអាក្រក់នេះ។ ប៉ុន្តែ អត្ថបទជាភាសាហេព្រើរដើមគ្រាន់តែនិយាយថា ពួកគេ "នឹងមានចិត្តរឹងប៉ឹង" ប៉ុណ្ណោះ។ ការប្រើពាក្យនេះ ប្រៀបដូចជាសែកទទេមួយដែល "ពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន" អាចសរសេរអ្វីក៏បាននៅលើវា។ និយាយម្យ៉ាងទៀត គ្មានអ្វីដែលអ្នកជឿមិនអាចធ្វើបានឡើយ។ ប៉ុន្តែ ឃ្លាដែលសមនឹងទទួលបានការយកចិត្តទុកដាក់របស់យើងទាំងស្រង គឺឃ្លានេះ៖ *"ពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន គេនឹងមានចិត្តរឹងប៉ឹង"* ។

សុវត្ថិភាពដ៏ពិតប្រាកដ

នៅទីបំផុត ប្រភពតែមួយគត់ដែលមានសុវត្ថិភាពសម្រាប់កម្លាំង និងអំណាច ដែលយើងគ្រប់គ្នាអាចពឹងផ្អែកបាន គឺការស្គាល់ព្រះ។ អស់រយៈពេលជាច្រើនឆ្នាំមកនេះ ខ្ញុំបានជួបគ្រីស្ទបរិស័ទមកពីស្ទើរតែគ្រប់និកាយ និងគ្រប់ក្រុមផ្សេងៗនៅក្នុងពួកជំនុំ។ គួរឲ្យស្តាយ មនុស្សភាគច្រើនក្នុងចំណោមពួកគេមិនអាចត្រូវបានពិពណ៌នាថា ជាមនុស្សរឹងមាំបានឡើយ។ ទោះបីជាពួកគេចាប់អារម្មណ៍លើប្រធានបទជាច្រើនដែលទាក់ទងនឹងជំនឿក៏ដោយ ក៏មនុស្សជាច្រើនក្នុងចំណោមពួកគេ មានពេលវេលាតិចតួចណាស់សម្រាប់ព្រះអង្គផ្ទាល់។


នៅពេលអ្នកអធិប្បាយបង្រៀនអំពីអំណាច មនុស្សម្នាក់ៗនាំគ្នាបើកត្រចៀកស្តាប់។ នៅពេលពួកគេផ្តោតលើការប្រោសឲ្យជា មនុស្សម្នានាំគ្នាមកជួបជុំយ៉ាងច្រើន។ នៅពេលពួកគេនិយាយអំពីទិដ្ឋភាពដ៏អស្ចារ្យនៃការបម្រើព្រះ មនុស្សហាក់ដូចជាត្រៀមខ្លួនរួចជាស្រេចដើម្បីស្តាប់។ ប៉ុន្តែកម្រណាស់ដែលខ្ញុំបានឮអ្នកអធិប្បាយនិយាយអំពីការស្គាល់ព្រះអង្គផ្ទាល់។ ហេតុអ្វីបានជាការផ្តោតលើរឿងនេះមានសារៈសំខាន់ខ្លាំងម្ល៉េះ? ខ្ញុំសូមផ្តល់ចម្លើយមួយ៖

ព្រោះអ្វីៗទាំងអស់ដែលមិនបានចាក់ឫសនៅក្នុងព្រះជាម្ចាស់ផ្ទាល់ នឹងត្រូវបក់បោកដោយរលកនៃអំពើអាក្រក់ដែលកំពុងកើនឡើងរៀងរាល់ឆ្នាំ។

ការជឿសាច "ព្រះជាម្ចាស់ បូកនឹងអ្វីផ្សេងទៀត"

ដូចដែលយើងបានឃើញហើយ មនុស្សជាច្រើននៅក្នុងពួកជំនុំសព្វថ្ងៃនេះ រំលងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអម្ចាស់។ ផ្ទុយទៅវិញ ពួកគេត្រូវបានរំខាន ឬជាប់រវល់ជាមួយនឹងការស្វែងរកអ្វីផ្សេងដែលជារឿងបន្ទាប់បន្សំ។ ពួកគេប្រហែលជាអាចដកស្រង់បទគម្ពីរ និងពិភាក្សាអំពីគោលលទ្ធិបានយ៉ាងស្ទាត់ជំនាញ ជាពិសេសនៅពេលពួកគេចង់ជជែកការពារទស្សនៈជាក់លាក់ណាមួយរបស់ខ្លួន។ ពេលខ្លះ មិនថាអ្នកព្យាយាមនិយាយជាមួយពួកគេអំពីរឿងអ្វីក៏ដោយ ពួកគេតែងតែបង្វែរការសន្ទនាត្រឡប់ទៅកាន់ប្រធានបទដែលខ្លួនផ្តោតលើជានិច្ច។ គួរឱ្យស្តាយ ពីព្រោះពួកគេកំពុងខកខានគោលបំណងសំខាន់បំផុតនៃការប្រោសលោះរបស់ពួកគេ គឺការស្គាល់ព្រះអម្ចាស់។

អកប្បកិរិយារបស់ពួកគេគឺ ត្រូវតែជា "ព្រះជាម្ចាស់ បូកនឹងអ្វីមួយទៀត"។ (ក្រមនីមួយៗក៏មាន "អ្វីមួយ" ខុសៗគ្នារបស់ខ្លួន)។ ពួកគេជឿថា "ព្រះជាម្ចាស់ បូកនឹងអ្វីមួយទៀត" នឹងធ្វើឲ្យពួកគេទទួលបានជោគជ័យ។ ទេ! ព្រះអង្គទេដែលនឹងសម្រេចកិច្ចការនោះ មិនមែន "អ្វីមួយទៀត" ទេ។ នៅពេលដែលយើងមានព្រះអង្គ យើងមិនត្រូវការអ្វីផ្សេង ឬអ្នកណាផ្សេងទៀតឡើយ។ មនុស្សដែលមានគំនិតថា "ព្រះជាម្ចាស់ បូកនឹងអ្វីមួយទៀត" គួរតែទៅអានព្រះគម្ពីរកូឡុស។ នៅទីនោះ លោកប៉ុល បាននិយាយយ៉ាងច្បាស់ថា៖ ព្រះយេស៊ូវគ្រីស្ទ គឺជាចម្លើយចុងក្រោយ។



ដ្បិតមានគ្រប់ទាំងសេចក្ដីពោរពេញរបស់ព្រះ សណ្ឋិតនៅក្នុងទ្រង់ទាំងមានរូបអង្គផង ហើយអ្នករាល់គ្នាក៏ពេញលេញក្នុងទ្រង់ ដែលទ្រង់ជាសិរសារលើអស់ទាំងពួកគ្រប់គ្រង នឹងអំណាចទាំងប៉ុន្មាន ។

(កូឡុស 2:9–10)

ព្រះយេស៊ូវ គឺជាចម្លើយតែមួយគត់។ យើងមិនត្រូវការ "ព្រះ បូកនឹងអ្វីផ្សេងទៀត" ឡើយ។ តាមពិតទៅ វាជាការប្រមាថដល់ព្រះ សម្រាប់អ្នកណាម្នាក់ដែលដាក់ព្រះយេស៊ូវគ្រីស្ទនៅក្នុងកម្រិតដូចគ្នានឹងព្រះពុទ្ធ សូក្រាត មូហាំម៉ាត់ ឬនរណាម្នាក់ ឬអ្វីមួយផ្សេងទៀត។

ការផ្តោតសំខាន់បំផុតរបស់យើង

មនុស្សខ្លះអាចរវល់ខ្លាំងជាមួយការទៅព្រះវិហារ ការអានព្រះគម្ពីរ ការស្វែងរកការអស្ចារ្យ ឬសូម្បីតែការផ្សព្វផ្សាយដំណឹងល្អ។ ទាំងអស់នេះសុទ្ធតែជាកិច្ចការល្អ ប៉ុន្តែប្រសិនបើការផ្តោតសំខាន់បំផុតរបស់យើង មិនមែនស្ថិតនៅលើព្រះអង្គទេ នោះយើងកំពុងខកខាន គោលបំណងចម្បងនៃសេចក្តីសង្គ្រោះរបស់យើង។ នៅពេលដែលយើងរំលងការស្គាល់ព្រះ នោះយើងបានខកខានអ្វីៗទាំងអស់។ ព្រះនៅតែប្រទានពរ និងជួយយើង។ ប៉ុន្តែ យើងនឹងខកខានគោលបំណងដែលទ្រង់មានសម្រាប់យើង។

បើអ្នក និងខ្ញុំអាចឮសម្លេងពីស្ថានសួគ៌បាន នោះយើងនឹងឮសម្លេងយ៉ាងខ្សឹបខ្សួលមួយ នៅក្នុងព្រះហឫទ័យរបស់ព្រះអម្ចាស់។ ព្រះអង្គនឹងមានព្រះបន្ទូលថា៖ "ពួកគេចង់បានអ្វីៗទាំងអស់ដែលយើងអាចប្រទានឲ្យ ប៉ុន្តែ ពួកគេមិនចាប់អារម្មណ៍ចង់ស្គាល់យើងឡើយ" ។

នេះក៏ជាការពិតសម្រាប់ខ្ញុំផងដែរ។ ក្នុងនាមជាទស្សនវិទូអាជីពម្នាក់ ខ្ញុំបានស្វែងរកចម្លើយសម្រាប់បញ្ហាជីវិតគ្រប់ទីកន្លែង (លើកលែងតែកន្លែងត្រឹមត្រូវ គឺព្រះជាម្ចាស់)។ នៅដំណាក់កាលដំបូងក្នុងជីវិត ខ្ញុំបានសន្និដ្ឋានថា គ្រីស្ទសាសនាមិនមែនជាចម្លើយទេ ដូច្នេះ ខ្ញុំបានបែរទៅរកទស្សនវិជ្ជាក្រិក យូដា និងគំនិតចម្លែកជាច្រើនផ្សេងទៀត។ ចុងក្រោយ នៅឆ្នាំ 1941 ក្នុងបន្ទប់យោធា ពេលគ្រប់គ្នាលង់លក់ ខ្ញុំបានជួបជាមួយព្រះអម្ចាស់យេស៊ូវគ្រីស្ទដោយផ្ទាល់។ នៅក្នុងការជួបជាមួយព្រះអម្ចាស់នោះ ខ្ញុំទទួលបាននូវចម្លើយ។

ក្រោយមក ខ្ញុំបានអានក្នុងគម្ពីរកូឡុស អំពីព្រះយេស៊ូវគ្រីស្ទថា៖ *"ដែលមានគ្រប់ទាំងជលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្ដីចេះដឹងលាក់ទុកក្នុងទ្រង់"* (កូឡុស 2:3)។

ខ្ញុំបាននិយាយក្នុងចិត្តថា៖ "ហេតុអ្វីខ្ញុំត្រូវបន្តកកាយរកក្នុងគំនរសំរាមនៃប្រាជ្ញាមនុស្សទៀត ខណៈដែលគ្រប់ទាំងជលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្តីចេះដឹងលាក់ទុកក្នុងព្រះយេស៊ូវគ្រីស្ទ?" ខ្ញុំបានសម្រេចថា ព្រះគម្ពីរគឺជាសៀវភៅដែលមានចម្លើយ ហើយខ្ញុំចង់ស្វែងរកក្នុងគ្រប់ទំព័រទាំងអស់ អំពីអ្វីដែលព្រះបានលាក់ទុកនៅក្នុងព្រះយេស៊ូវគ្រីស្ទ។ អ្វីៗទាំងអស់ដែលខ្ញុំធ្លាប់ស្វែងរកក្នុងទស្សនវិជ្ជា និងប្រាជ្ញាមនុស្ស ឥឡូវនេះខ្ញុំបានរកឃើញនៅក្នុងទ្រង់។

អាលថា និងអូមេកា

ចាប់តាំងពីពេលនោះមក ខ្ញុំក៏ធ្លាប់ត្រូវបានបង្វែរចិត្ត និងទាញចេញទៅកាន់ប្រធានបទបន្ទាប់បន្សំផ្សេងៗ